# វិហារវត្តដំរីស

វិហារវត្តដំរីស គឺស្ថិតនៅតាមដងស្ទឹងសង្កែ ក្នុងក្រុងបាត់ដំបង មានវត្តអារាមជាច្រើនកសាងឡើងសឹងតែមានលក្ខណៈសិល្បៈល្អប្លែកផ្នែកស្ថាបត្យកម្ម និងក្បាច់រចនាយ៉ាងវិចិត្រ។ តាមខ្លឹមសារកាព្យព្រះគ្រូចៅអធិការវត្តសូរភី ក្នុងសៀវភៅ "បាត់ដំបងសម័យលោកម្ចាស់" រាប់វត្តបុរាណតាមដងស្ទឹងនេះ សរុបមានចំនួន២០វត្ត។[១] ក្នុងចំណោមនោះ វត្តដំរីសស្ថិតនៅត្រើយខាងលិច ពោលគឺទីតាំងនៅមិនឆ្ងាយពីសាលាខេត្ត ដែលជាអតីតផ្ទះរបស់លោកម្ចាស់គទាធរឈុំ។[២] វត្តនេះមានឈ្មោះមួយផ្សេងទៀតដែរថា "ស្វេតឆត្រកុញ្ជរជ័យ" ហើយក៏ជាវត្តចំណាស់ក្នុងបណ្តាវត្តទាំងឡាយនៅតាមដងស្ទឹងសង្កែ។

វិហារវត្តដំរីស ជាសំណង់ស្ថាបត្យកម្មព្រះពុទ្ធសាសនាដ៏ល្អធើតមួយនៅក្នុងរាជ្យ**ព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ "ព្រះរាជានុកោដ្ឋ"**។ សំណង់នេះជាទម្រង់វិហារមណ្ឌប ដំបូលក្បឿងស្រកាលេញបីថ្នាក់ និងមានកំពូលបុស្បុកស្រួចនៅលើដំបូល លំនាំដូចវិហារព្រះកែវមរកតក្នុងព្រះបរមរាជវាំង។ ប៉ុន្តែវិហារវត្តដំរីស មានតែជហ្ជាបីខាងមុខ និងជហ្ជាបីខាងក្រោយប៉ុណ្ណោះ។[៣] វិហារនេះសង់នៅលើខឿនពីរថ្នាក់ មានសសរ៦ជួរបណ្តោយ និង១២ជួរទទឹង សរុបមានសសរចំនួន៧២ដើម។ សសរខាងក្នុងមានកម្ពស់ប្រហែល៩ ម៉ែត្រ រចនាដោយក្បាច់ផ្កាភ្ញីយ៉ាងរស់រវើក។ ខាងមុខមានទ្វារ២ ខាងក្រោយទ្វារ២ និងមានបង្អួចម្ខាង៧ រចនាដោយស៊ុមក្បាច់យ៉ាងវិចិត្រ។ រីឯព្រះជីវគង់ក្នុងកាយវិការផ្ចាញ់មារ លើបល្ល័ង្កខ្ពស់ និងរចនាដោយក្បាច់ដាំកញ្ចក់យ៉ាងភ្លឺផ្លេក។

កន្លងមក គេដឹងថាវិហារវត្តដំរីសធ្លាប់បានជួសជុលច្រើនលើក ហើយការជួសជុលចុងក្រោយនៅក្នុងឆ្នាំ២០១៥។ រាល់ការជួសជុលម្តងៗ គេតែងប្រើប្រាស់សម្ភារៈសំណង់ថ្មីមួយចំនួនជំនួសចំណុចដែលយកតាមលំនាំចាស់។ ដោយឡែកគំនូរលើជញ្ជាំងខាងក្នុង

---

[១] តូច ឈួង ១៩៩៤: ១៦៩-១៧០

[២] លោកជាស្តេចត្រាញ់នៃវង្សត្រកូលចៅហ្វាបែន។ ក្រោយបានឡើងជាស្តេចត្រាញ់ លោកមានងារថា "ចៅពញាគទាធរធរណិន្ទ្ររាមនរិន្ទឥន្ទ្រាធិបតីអភ័យភេរីពាហុ"។

[៣] ព្រាប ចាន់ម៉ារ៉ា ២០០៥: ២៩-៣៣

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

វិហារនិយាយអំពីពុទ្ធប្រវត្តិ គូរក្នុងរវាងទសវត្សទី៨០។[៨] នៅលើជញ្ជាំងផ្នែកខាងក្រៅ ត្រង់បន្ទាត់ខាងលើលម្អដោយគំនូរបុរាណ និយាយពីរឿងមហាវេស្សន្តរជាតក និងពុទ្ធប្រវត្តិ។ ចំណែកបន្ទាត់ខាងក្រោម លម្អដោយអន្ទើខ្ទីៗស្រង់ពីរឿងរាមកេរ្តិ៍ រចនាជាចម្លាក់ស៊ីម៉ងត៍ស្តើងៗ។ នៅលើជញ្ជាំងខាងកើត និងខាងលិច ត្រង់ចន្លោះទ្វារនីមួយៗមានចម្លាក់ឈុតរាមកេរ្តិ៍ពីរផ្ទាំងធំៗ។ ផ្នែកខាងកើត ជាឈុតចម្បាំងរវាងព្រះរាម និងក្រុងរាពណ៍។ ផ្នែកខាងលិច ជាឈុតចម្បាំងរវាងព្រះលក្ស្មណ៍ និងឥន្ទ្រជិត។

ចំពោះការតុបតែងលម្អនៅលើក្បាលសសរខាងក្រៅវិហារ គេបានរចនាយកតាមលំនាំទេវកថា ជារូបគ្រុឌហែកនាគយ៉ាងអង់អាចក្រៃលែង។ រីឯការរចនាលើផ្ទៃហោជាងខាងមុខនិងខាងក្រោយ មានលក្ខណៈស្មើរដូចគ្នាបេះបិទ។ ចំណុចសំខាន់នៃផ្ទៃហោជាងទាំងនោះ គឺការរំលេចរូបកមុជ ស្វេតឆត្រ និងកេតនកណ្ឌាផ្សេងៗនៅលើពាក្យ "ខេមរៈ" នៅលើជើងពាន ដែលមានទេវតាសាទរហោះទ្រលេចចេញពីផ្ទៃក្បាច់រចនាយ៉ាងរស់រវើក។ ការរំលេចបង្ហាញនូវរូបមកុដ និងកេតនកណ្ឌាទាំងនេះ ក៏ឃើញនៅលើហោជាងនៃស៊ុមចម្លាក់ឈុតរាមកេរ្តិ៍ទាំងពីរផ្ទាំងធំៗនោះដែរ។ នៅគែមសងខាងនៃហោជាង មានពាក្យគួរឱ្យកត់សម្គាល់ពីរម៉ាត់គឺ "សង្គមកសាង" ធ្លាក់នៅគែមខាងឆ្វេង និងពាក្យ "សម្រាប់ពុទ្ធសាសនា" នៅគែមខាងស្តាំ។

យោងតាមបទសម្ភាសរបស់វិទ្យុបារាំង *RFI* ជាមួយព្រឹទ្ធាចារ្យ ឡុច ឆានឆាយ ដែលលោកធ្លាប់ស្រង់គំនិតក្នុងសៀវភៅបាត់ដំបងសម័យលោកម្ចាស់ ធ្វើនិក្ខេបបទបញ្ចប់ការសិក្សាឱ្យដឹងថា វិហារវត្តដំរីសសាងសង់ឡើងនៅចន្លោះឆ្នាំ១៨៩៥-១៩០០ ក្នុងគ្រាដែលខេត្តបាត់ដំបងនៅជាចំណុះសៀម។[៩] ប៉ុន្តែបើតាមការសិក្សារបស់ *Daniel Guéret* និង *Dominique-Pierre Guéret* វិហារវត្តនេះសង់នៅរវាងឆ្នាំ១៩០៤ ពោលគឺប្រហាក់ប្រហែលគ្នានឹងវិហារវត្តពិភិទ្ធ ដែលស្ថិតនៅត្រើយខាងលិចស្ទឹងដូចគ្នា។[៦] ការយល់ឃើញដូច្នេះទំនង

---

[៨] Daniel Guéret & Dominique-Pierre Guéret 2017: 156

[៩] www.rfi.fr/km/ ផ្សាយថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២១

[៦] Daniel Guéret & Dominique-Pierre Guéret 2017: 156

អត្ថបទដោយៈ ហៀន សុវណ្ណមរកត

ដោយសារម្ខាងផ្អែកលើការសិក្សាតាមការនិទានរបស់អ្នកស្រុក និងម្ខាងទៀតសម្អាងលើការពិនិត្យលក្ខណៈសិល្បៈស្ថាបត្យកម្មនៃសំណង់។ ចំពោះឈ្មោះអ្នកកសាងវិហារទៀតសោត ក៏មានសេចក្ដីបញ្ជាក់ទីទៃពីគ្នាដែរ។ អត្ថបទខ្លះលើកឡើងថា វត្តនេះសង់ឡើងដោយសទ្ធារបស់ជំទាវ អ៊ីង ជាភរិយាលោកម្ចាស់ឃុំ ឬខ្លះថាកសាងដោយលោកម្ចាស់ឃុំមុនលោកទៅរស់នៅខេត្តបសិ្ចម ក្នុងស្រុកសៀម។ ប៉ុន្តែក្នុងបទសម្ភាសខាងលើបញ្ជាក់ថាបិតារបស់ជំទាវ អ៊ីង ជាអ្នកមានសទ្ធាផ្ដើមដឹកនាំសង់វិហារនេះដើម្បីលាបំណន់។ តាមឯកសាររបស់លោក តូច ឈួង ឱ្យដឹងថាក្រុមជាងដែលមានទឹកដៃវិសេសក្នុងផ្នែករចនាក្បាច់ក្បូរផ្សេងៗ រួមទាំងរូបគ្រុឌ តោ ស្វា ទេវតា មនុស្ស យក្ស... លម្អវិហារវត្តដំរីស គឺជាងញឹក មានលំនៅនៅព្រែកតាតន់ និងជាងសឿន នៅភូមិចម្ការសំរោង។[៧]

ជារួមមកទឹកដៃសិល្បៈស្ថាបត្យកម្មនៃវិហារវត្តដំរីសនេះ ស្ដែងឱ្យឃើញពីចំណេះជំនាញកើតចេញពីអ្នកស្រុកសុទ្ធសាធ។ រីឯប្រធានបទសិល្បៈដែលលើកមកលម្អ ហាក់មានលក្ខណៈចម្រុះ ពោលគឺស្រង់ចេញពីរឿងរាមកេរ្តិ៍ រឿងពុទ្ធប្រវត្តិ និងទេពកថានានាផង។

អរិយធម៌ខ្មែរ
KHMER CIVILIZATION

[៧] តូច ឈួង ១៩៩៤: ៩០

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# បញ្ជីរូបភាព




រូបលេខ១-២ ទិដ្ឋភាពវិហារវត្តដំរីសមើលពីទិសខាងត្បូង និងទិសអាគ្នេយ៍




រូបលេខ៣-៤ ចម្លាក់រូបគ្រុឌហែកនាគតាមក្បាលសសរទ្រទ្រង់ស្បូវ




រូបលេខ៥-៦ ក្បាច់រចនា និងអក្សរចារឹកលើផ្ទៃហោជាងខាងកើត និងខាងលិច

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៧ ក្បាច់រចនាស៊ុមបង្អួច



រូបលេខ៨ ព្រះលក្ស្មណ៍ច្បាំងនឹងឥន្ទ្រជិត



រូបលេខ៩ ព្រះរាមច្បាំងនឹងក្រុងរាពណ៍



រូបលេខ១០ ការជួសជុលកន្លងមក



រូបលេខ១១ របៀងវិហារ



រូបលេខ១២ ទិដ្ឋភាពក្នុងវិហារ



រូបលេខ១៣ ការរចនាលើខឿនវិហារ



រូបលេខ១៤ ការរចនាសាច់រឿងលើជញ្ជាំងខាងក្រៅ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត




រូបលេខ១៥-១៦ ការរចនារឿងជាតកនៅបន្ទាត់ខាងលើ និងរឿងរាមកេរ្តិ៍នៅបន្ទាត់ខាងក្រោម



រូបលេខ១៧ ស្វាជិះរថភ្លើង



រូបលេខ១៨ ពិធីរាជាភិសេក



រូបលេខ១៩ ជជូកព្រាហ្មណ៍ និងព្រានព្រៃ



រូបលេខ២០ នាងមេទ្រីបេះផ្លែផល្លា

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

តូច ឈួង

១៩៩៤, *បាត់ដំបងសម័យលោកម្ចាស់*, មជ្ឈមណ្ឌលបូព៌ា-បស្ចិម, ហូណូលូលូ រដ្ឋហាវ៉ៃ

ព្រាប ចាន់ម៉ារ៉ា

២០១៧, *សំណង់នៅតាមវត្ត*, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ

Daniel Guéret & Doninique-Pierre Guéret

2017, *The Khmer Pagoda,* Kam editions

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត